# របាយការណ៍

## សិក្ខាសាលាថ្នាក់តំបន់ពិនិត្យមើលលទ្ធផលនៃការស្វែងរកអ្នកផ្ទុកមេរោគអេដស៍ និងការពង្រឹងគុណភាពនៅសេវាបង្ការ ថែទាំ និងព្យាបាលបន្ត ទៅតាមវដ្ត ការធ្វើផែនការ-ការអនុវត្ត-ការពិនិត្យមើល-ការកែតម្រូវសកម្មភាព (IACM-CQI)

៚៚✵៙៙

ចាប់ថ្ងៃចន្ទ ៦រោច ដល់ថ្ងៃអង្គារ ៧រោច ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី ២៩ ដល់ ៣០ ខែមេសា ឆ្នាំ២០២៤ **លោកវេជ្ជបណ្ឌិត ង៉ូវ ប៉ូរ៉ា អនុប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ** តំណាងដ៏ខ្ពង់ខ្ពស់របស់ **លោកសាស្ត្រាចារ្យជំនួយ អ៊ុក វិច្ឆា ប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ** បានដឹកនាំសិក្ខាសាលាថ្នាក់តំបន់ពិនិត្យមើលលទ្ធផលនៃការស្វែងរកអ្នកផ្ទុកមេរោគអេដស៍ និងការពង្រឹងគុណភាពនៅសេវាបង្ការ ថែទាំ និងព្យាបាលបន្ត ទៅតាមវដ្ត ការធ្វើផែនការ-ការអនុវត្ត-ការពិនិត្យមើល-ការកែតម្រូវសកម្មភាព ដែលប្រព្រឹត្តិទៅនៅមន្ទីរសុខាភិបាលខេត្តកំពត ឧបត្ថម្ភថវិកាដោយ US-CDC មានសិក្ខាកាមអញ្ជើញចូលរួម ១៥ រាជធានី/ខេត្ត។ វគ្គសិក្ខាសាលានេះក្រោមអធិបតីភាពរបស់ លោកវេជ្ជបណ្ឌិត ង៉ូវ ប៉ូរ៉ា អនុប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ លោកវេជ្ជបណ្ឌិត តាំង ឆេង អនុប្រធានមន្ទីរសុខាភិបាលខេត្តកំពត និងលោកវេជ្ជបណ្ឌិត លី វណ្ណជី អនុប្រធានមជ្ឈមណ្ឌលប្រយុទ្ធនឹងជំងឺឆ្លងសហរដ្ឋអាមេរិក។

សិក្ខាសាលានេះមានគោលបំណងរួម គឺដើម្បីធានានូវសមាមាត្រខ្ពស់ នៃល្បាក់ទាំងមូលតាំងពីការរកឃើញអ្នកផ្ទុកមេរោគអេដស៍រហូតដល់ការចុះឈ្មោះ និងទទួលសេវាថែទាំ និងព្យាបាលប្រកបដោយគុណភាព។

គោលបំណងជាក់លាក់៖

- ពិនិត្យលទ្ធផលសម្រេចបាននៃសូចនាករ៖
  សូចនាករសំខាន់ៗ ៥ របស់ ACM
  1. ចំនួនករណីប្រតិកម្មរកឃើញថ្មី (reactive cases)
  2. ចំនួនករណីប្រតិកម្មថ្មីមានតេស្តបញ្ជាក់វិជ្ជមាន (confirmed HIV+)
  3. % recency test (RTRI) វិជ្ជមាន
  4. % អ្នកមានតេស្តបញ្ជាក់វិជ្ជមានចុះឈ្មោះក្នុងសេវាART
  5. % អ្នកចុះឈ្មោះក្នុងសេវាARTបានទទួលនិងចាប់ផ្តើមART

សូចនាករ នៃសេវាថែទាំ និងព្យាបាលប្រកបដោយគុណភាព

1. % អ្នកជំងឺART ដែលបានស្លាប់
2. % អ្នកជំងឺARTខកណាត់ ≤28ថ្ងៃដែលបានដាក់ឱ្យទទួលសេវាវិញ
3. % អ្នកជំងឺបាត់មុខ >28ថ្ងៃ ដែលបានដាក់ឱ្យទទួលសេវាវិញ
4. % ការមកពិនិត្យតាមការណាត់, មុនថ្ងៃណាត់, យឺតនៅថ្នាំបម្រុង, យឺតអស់ថ្នាំបម្រុង
5. % អ្នកជំងឺផ្តើមARTថ្មីនៅក្នុងត្រីមាសដែលចាប់ផ្តើមការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ក្នុងថ្ងៃតែមួយនឹងថ្ងៃធ្វើរោគវិនិច្ឆ័យថាមានផ្ទុកមេរោគអេដស៍
6. % អ្នកជំងឺបាននិងកំពុងទទួលឱសថនិងការណាត់ជួប ≥3 months
7. % អ្នកជំងឺផ្តើមARTថ្មីដំបូងដោយឱសថTLD
8. % អ្នកជំងឺសរុបបានទទួល ឱសថ TLD មកទល់នឹងចុងត្រីមាសរាយការណ៍
9. % អ្នកជំងឺដែលសមស្របធ្វើVL តេស្តនៅក្នុងត្រីមាស បានធ្វើVLតេស្ត
10. % លទ្ធផលVLតេស្តបានត្រឡប់មកដល់គ្លីនិកវិញក្នុងអំឡុងពេល១០ថ្ងៃ
11. % អ្នកជំងឺ on ARTបានធ្វើតេស្តVL ក្នុងអំឡុងពេល១២ខែកន្លងមក (VL testing coverage)
12. % អ្នកជំងឺ on ARTមានVL suppressed (WHO VLS.3 program-level denominator)
13. % អ្នកជំងឺ on ARTមានVL suppressed (WHO VLS.3 population-level denominator)
14. % អ្នកជំងឺដែលបានបញ្ចប់TPT នៅចុងត្រីមាសរាយការណ៍
15. អត្រាអ្នកជំងឺបន្តបិតនៅក្នុងសេវាARTរបស់យើង Retention rate
16. ចំនួនលទ្ធផល Viral Load Test បានទទួលបានតាមត្រីមាសនីមួយៗ បែងចែកតាមប្រភេទ <40, 40-999 និង 1000+ ឆ្នាំ 2021-2023
17. បច្ចុប្បន្នភាព ការពង្រឹង EAC ករណីអ្នកជំងឺដែលមាន Viral Load 40-999 និង ≥1000

- កំណត់បញ្ហាអាទិភាព និងមូលហេតុដែលបណ្តាលឱ្យលទ្ធផលរបស់សូចនាករធ្លាក់ចុះ
- រៀបចំផែនការសកម្មភាពដើម្បីកែលម្អ។

របៀបវារៈ

| ម៉ោង | មាតិកា | គ្រូសម្របសម្រួល |
|---|---|---|
| ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០២៤ | | |
| ០៧:៣០-០៨:០០ | ការចុះឈ្មោះ | មជ្ឈមណ្ឌលជាតិ |

| | | |
|---|---|---|
| ០៨:០០-០៨:៤៥ | • មតិចំណាប់អារម្មណ៍ ស្វាគមន៍ដោយលោកវេជ្ជ. តាំង ឆេង អនុប្រធានមន្ទីរសុខាភិបាលខេត្តកំពត<br>• មតិចំណាប់អារម្មណ៍ដោយលោកវេជ្ជ. លី វណ្ណធី អនុប្រធានមជ្ឈមណ្ឌលប្រយុទ្ធនឹងជំងឺឆ្លងសហរដ្ឋអាមេរិក<br>• មតិសំណេះសំណាល និងប្រកាសបើកវគ្គសិក្ខាសាលាដោយលោកវេជ្ជ. ង៉ូវ បូរ៉ា អនុប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ | មជ្ឈមណ្ឌលជាតិ |
| ០៨:៤៥-០៩:០០ | ការរំពឹងទុក វិន័យវគ្គសិក្ខាសាលា | មជ្ឈមណ្ឌលជាតិ |
| **០៩:០០-០៩:១០** | **សម្រាកអាហារសម្រន់** | |
| ០៩:១០-១០:៣០ | - បង្ហាញ MPOX<br>- បង្ហាញពី លទ្ធផលនៃការអនុវត្តការងារថែទាំ-ព្យាបាលជំងឺអេដស៍ ត្រឹមត្រីមាសទី១ ឆ្នាំ២០២៤ របស់មជ្ឈមណ្ឌលជាតិ | វេជ្ជ ង៉ូវ បូរ៉ា<br>វេជ្ជ. ប្រាក់ ណារុំ<br>វេជ្ជ ចាន់ សូដារា |
| ១០:៣០-១២:០០ | - ពិនិត្យ លទ្ធផលនៃការអនុវត្តការងារថែទាំ-ព្យាបាលជំងឺអេដស៍ ត្រឹមត្រីមាសទី១ ឆ្នាំ ២០២៤ របស់សេវាART នៃមន្ទីរពេទ្យខេត្តតាកែវ មន្ទីរពេទ្យបង្អែកគិរីវង់ មន្ទីរពេទ្យបង្អែកព្រៃកប្បាស មន្ទីរពេទ្យបង្អែកអង្គរកា មន្ទីរពេទ្យបង្អែកខេត្តព្រះសីហនុ និងមន្ទីរពេទ្យបង្អែកខេត្តប៉ៃលិន<br>(សំនួរ & ចម្លើយ) | **ប្រធាន** ART តំណាងសេវាART នៃមន្ទីរពេទ្យនីមួយៗ |
| **១២:០០-១៣:៣០** | **សម្រាកអាហារថ្ងៃត្រង់** | |
| ១៣:៣០-១៥:០០ | - ពិនិត្យ លទ្ធផលនៃការអនុវត្តការងារថែទាំ-ព្យាបាលជំងឺអេដស៍ ត្រឹមត្រីមាសទី១ ឆ្នាំ ២០២៤ របស់សេវាART នៃមន្ទីរពេទ្យខេត្តកំពង់ស្ពឺ មន្ទីរពេទ្យបង្អែកឧដុង្គ មន្ទីរពេទ្យគងពិសី មន្ទីរពេទ្យបង្អែកខេត្តកំពត មន្ទីរពេទ្យបង្អែកកំពង់ត្រាច មន្ទីរពេទ្យបង្អែកកំពង់ធំ មន្ទីរពេទ្យបង្អែកបារាយណ៍-សន្ទុក និងមន្ទីរពេទ្យបង្អែកកែប (សំនួរ & ចម្លើយ) | **ប្រធាន** ART តំណាងសេវាART នៃមន្ទីរពេទ្យនីមួយ៍ |
| **១៥:០០-១៥:១៥** | **សម្រាកអាហារសម្រន់** | |
| ១៥:១៥-១៦:៤៥ | - ពិនិត្យ លទ្ធផលនៃការអនុវត្តការងារថែទាំ-ព្យាបាលជំងឺអេដស៍ ត្រឹមត្រីមាសទី១ ឆ្នាំ ២០២៤ របស់សេវាART នៃមន្ទីរពេទ្យបង្អែកខេត្តពោធិ៍សាត់ មន្ទីរពេទ្យបង្អែកក្រវ៉ាញ មន្ទីរពេទ្យបង្អែកបាកាន មន្ទីរពេទ្យបង្អែកសំពោង មន្ទីរពេទ្យបង្អែកអន្លង់វែង មន្ទីរពេទ្យបង្អែក១៦មករា មន្ទីរពេទ្យបង្អែកកោះកុង និងមន្ទីរពេទ្យបង្អែកស្រែអំបិល<br>(សំនួរ & ចម្លើយ) | **ប្រធាន** ART តំណាងសេវាART នៃមន្ទីរពេទ្យខេត្តនីមួយៗ |
| ១៦:៤៥-១៧:០០ | សង្ខេបថ្ងៃទី០១ និងសំណួរ & ចម្លើយ | គ្រូសម្របសម្រួលទាំងអស់ |
| **ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០២៤** | | |
| ០៨:០០-០៩:៣០ | - ពិនិត្យ លទ្ធផលនៃការអនុវត្តការងារថែទាំ-ព្យាបាលជំងឺអេដស៍ ត្រឹមត្រីមាសទី១ ឆ្នាំ ២០២៤ របស់សេវាART នៃមន្ទីរពេទ្យជ័យជំនះ មន្ទីរពេទ្យបង្អែកកោះធំ មន្ទីរពេទ្យបង្អែកកៀនស្វាយ មន្ទីរពេទ្យបង្អែកខេត្តកំពង់ឆ្នាំង មន្ទីរពេទ្យបង្អែកកំពង់ត្រឡាច មន្ទីរពេទ្យបង្អែកខេត្តត្បូងឃ្មុំ មន្ទីរពេទ្យបង្អែកព្រះនរោត្តមសីហនុត្បូងឃ្មុំ និងមន្ទីរពេទ្យបង្អែកមេមត់ | **ប្រធាន** ART តំណាងសេវាART នៃមន្ទីរពេទ្យខេត្តនីមួយៗ |

| | | |
|---|---|---|
| | (សំនួរ & ចម្លើយ) | |
| ០៩:៣០-១០:៣០ | - ពិភាក្សាក្រុម (សេវាART នីមួយៗ ពិនិត្យលទ្ធផលដែលនៅមានកំរិត និង ពិភាក្សាជ្រើសរើសបញ្ហាជាអាទិភាព សម្រាប់ដោះស្រាយ និងធ្វើផែនការកែលម្អសេវា អោយកាន់តែមានប្រសិទ្ធិភាពខ្ពស់) | គ្រូសម្របសម្រួល និងអ្នកចូលរួមទាំងអស់ |
| **១០:៣០-១០:៤៥** | **សម្រាកអាហារសម្រន់** | |
| ១០:៤៥-១២:០០ | - ធ្វើការបង្ហាញ លទ្ធផលកិច្ចពិភាក្សា និង ផែនការកែលម្អសេវា (សេវាART នីមួយៗ មានរយៈ ពេល ១៥នាទី ក្នុងការបង្ហាញ និង ៥នាទីសម្រាប់សំនួរ-ចម្លើយ)- ២៩ សេវា | គ្រូសម្របសម្រួល និងអ្នកចូលរួមទាំងអស់ |
| **១២:០០-១៣:៣០** | **សម្រាកអាហារថ្ងៃត្រង់** | |
| ១៣:៣០-១៥:៣០ | - សរុបលទ្ធផលនៃកិច្ចពិភាក្សាពីបញ្ហាដែលទាក់ទងនឹងការអនុវត្តនៅមានកំរិត (រកឬសគល់នៃបញ្ហា) តាមសេវា/ខេត្តនីមួយៗ | ផ្នែកថែទាំជំងឺអេដស៍ គ្រូសម្របសម្រួល |
| **១៥:៣០-១៥:៤៥** | **សម្រាកអាហារសម្រន់** | |
| ១៥:៤៥-១៦:១៥ | - សេចក្តីសន្និដ្ឋាន និង ធ្វើការវាយតម្លៃវគ្គសិក្ខាសាលា | មជ្ឈមណ្ឌលជាតិ |
| ១៦:១៥-១៦:៤៥ | - បិទវគ្គសិក្ខាសាលា | មជ្ឈមណ្ឌលជាតិ |

រូបថតសកម្មភាព




